YUNNAN DAILY PRESS GROUP

សម្រស់ យូនណាន

ទស្សនាវដ្ដី ប្រចាំថ្ងៃ

YUNNAN DAILY PRESS GROUP
english.yunnan.cn

ឆ្នាំទី 23 លេខ 6722 ថ្ងៃសុក្រ ទី 15 ខែឧសភា ឆ្នាំ 2015

ទីក្រុងគុនមីញ: "CPU" កំពុងរត់យ៉ាងឆាប់រហ័ស

នៅពេលចុងនិទាឃ:រដូវនេះ នៅសង្កាត់ឆឹងកុង ទីក្រុងគុនមីញ ខេត្តយូនណាន ស្ថានីយរថភ្លើងថ្មីនៃទីក្រុងគុនមីញ ដែលមានទំហំ ៣៣០.០០០ ម៉ែត្រក្រឡានោះ កំពុងខ្ពស់ឡើងៗជារៀងរាល់ថ្ងៃ ។ ក្រោយពីការចាប់ប្រើការនៃផ្លូវដែកដ៏មានល្បឿនខ្ពស់នៅខែមិថុនាឆ្នាំ២០១៦ ពីទីក្រុងគុនមីញ ដល់ទីក្រុងសៀងហៃ និងទីក្រុងឆាងសា គ្រាន់តែត្រូវការ៨ម៉ោងនិង៤ម៉ោង នឹងសម្រេចការតភ្ជាប់ជាមួយទូទាំងប្រទេស ។ ស្ថានីយរថភ្លើងថ្មីនៃទីក្រុងគុនមីញមានវេទិកាចាំរថភ្លើងចំនួន១៦ និងមានផ្លូវដែកចំនួន៣០ខ្សែ គឺជាមជ្ឈមណ្ឌលចរាចរណ៍សំខាន់មួយនៃបណ្ដាញផ្លូវដែក"ផ្លូវដែកចេញពីខេត្តទាំង៨និងផ្លូវដែកចេញព្រំដែនទាំង៤" នៃខេត្តយូនណាន ។ ទីក្រុងគុនមីញដែលជា "CPU"នៃការបើកចំហចំពោះទិសនិរតីនេះ កំពុងរត់យ៉ាងឆាប់រហ័សហើយកើនតែឆាប់ឡើងជារៀងរាល់ថ្ងៃ ។

ក្នុងផែនការ "ក្រវាត់មួយ និងផ្លូវមួយ"នៃប្រទេសចិនបានថែងថា ជំរុញការសាងសង់នៃច្រកអន្តរជាតិរវាងខេត្តយូនណាន និងប្រទេសជិតខាងដោយពឹងផ្អែកលើឧត្តមភាពខាងភូមិសាស្ត្រនៃខេត្តយូនណាន ដើម្បីកសាងវេទិកាសហការថ្មីដ៏មានកម្រិតខ្ពស់សម្រាប់ការសហប្រតិបត្តិការក្នុងអនុតំបន់មហាទន្លេមេគង្គធ្វើឱ្យខេត្តយូនណានក្លាយជាមជ្ឈមណ្ឌលជាវិទ្យុសកម្មដែលប្រឈមនឹងអាស៊ីខាងត្បូងនិងអាស៊ីអាគ្នេយ៍ ។ លោក លីអ៊ូន-យ៉ុង អភិបាលក្រុងនៃទីក្រុងគុនមីញបានថ្លែងថា "យើងសន្មតទីក្រុងគុនមីញជា"CPU"នៃមជ្ឈមណ្ឌលជាវិទ្យុសកម្មដែលប្រឈមនឹងអាស៊ីខាងត្បូង និងអាស៊ីអាគ្នេយ៍"។

នៅម៉ោង១១ ថ្ងៃ១៣ ខែមេសានេះ នៅតាមច្រកអន្តរជាតិនៃស្រុកហឺខូវ រថភ្លើងលេខ១២០៨ ដែលជារថភ្លើងដឹកជញ្ជូនរួមគ្នាអន្តរជាតិនៃប្រទេសចិននិងវៀតណាមបានឆ្លងកាត់ស្ពានចិន-វៀតណាម ហើយបើកបរឆ្ពោះទៅទីក្រុងឡៅកៃ ប្រទេសវៀតណាមដោយពោរពេញទៅដោយជីគីមីនៃប្រទេសចិន ។ "ក្រោយពីការប្រើការនៃផ្លូវដែកគុនមីញ-យីស៊ី-ហឺខូវ បរិមាណដឹកជញ្ជូននៃប្រទេសចិននិងវៀតណាមក្នុងឆ្នាំ១២០៤ បានមានដល់ទៅ៣.៤០០តោន" លោកចុង ហៃយុង ស្នងការនយោបាយនៃប៉ុស្តិ៍ត្រួតពិនិត្យស្រុកហឺខូវ បានណែនាំ ។ ទន្ទឹមនឹងការសាងសង់នៃបណ្ដាញផ្លូវដែកទំនើបដ៏មានប្រសិទ្ធភាព សុវត្ថិភាព និងភាពងាយស្រួលនៃខេត្តយូនណាន ឋានៈជាមជ្ឈមណ្ឌលចរាចរណ៍អន្តរជាតិក្នុងតំបន់និងមជ្ឈមណ្ឌលដឹកជញ្ជូនអន្តរ-ជាតិនៃទីក្រុងគុនមីញបានលេចរូបរាង

កាន់តែច្បាស់លាស់ ។

ផ្សារគូវណាននៃទីក្រុងគុនមីញ គឺជាផ្សារផ្កាធំជាងគេក្នុងទូទាំងទ្វីបអាស៊ី បាននាំចេញផ្កាឆ្ពោះទៅ ៤៦ ប្រទេស ឥឡូវនេះផ្សារនេះចាប់ផ្ដើមអនុវត្តន៍វិក្កយបត្រអេឡិចត្រូនិក និងពាណិជ្ជកម្មអេឡិចត្រូនិក ។ យោងតាមធនធានធម្ម-ជាតិ លក្ខណៈពិសេសឧស្សាហកម្ម និងនិន្នាការអភិវឌ្ឍរបស់បណ្ដាប្រទេសជិតខាងក្រុងគុនមីញខំស្វែងរកចំណុចសហការជាមួយនឹងអាស៊ីខាងត្បូង និងអាស៊ីអាគ្នេយ៍ សម្រាប់កសិកម្ម ឧស្សាហកម្មផ្កា ការជីកយករ៉ែ វារីអគ្គិសនីនិងឧស្សាហកម្មឱសថនៃខេត្តយូនណាន។

បំពង់បង្ហូរប្រេងឆៅ ចិន-ភូមា គ្រឿងបន្ទាប់បន្សំនៃសន្និសីទកំពូលអាស៊ី-អឺរ៉ុបនៅប្រទេសឡាវ វិទ្យាស្ថានយោធាជើងគោកនៃប្រទេសកម្ពុជា ផ្លូវព្រលានយន្តហោះថ្មីនៃក្រុងឡាបូ របស់ប្រទេសហ្គីណេ អេក្វាទ័រ។ល។ កម្មវិធីសាងសង់ខាងលើនេះ សុទ្ធតែអនុវត្តន៍ដោយក្រុមហ៊ុនសំណង់ខេត្តយូនណាន ។ ៣ឆ្នាំកន្លងមកនេះ ក្រុមហ៊ុនសំណង់ខេត្តយូនណាន បានឈ្នះការដេញថ្លៃកម្មវិធីចំនួន ៥៩ នៅក្រៅប្រទេស។

ឧស្សាហកម្មទេសចរណ៍ និងវប្បធម៌ជាឧស្សាហកម្មដឹកនាំដើម្បីបង្កើតទំនាក់ទំនងកាន់តែជិតស្និទ្ធសម្រាប់គ្រប់ទីក្រុងក្នុងតំបន់សេដ្ឋកិច្ច"ក្រវាត់មួយ និងផ្លូវមួយ"។ រឿងភាគទូរទស្សន៍ទាំង៩ច្បាប់ដូចជា"រឿងក្នុងគេហដ្ឋានរបស់ត្រកូលម្ញូ" "សម័យដ៏ស្រស់ស្អាតសម្រាប់កូនប្រសាស្រី" និង "យុវជនប៉េកាំង" ជាដើម ដែលសុទ្ធតែបកប្រែដោយក្រុមហ៊ុនក្នុងសួនឧស្សាហកម្មផ្សព្វផ្សាយពាណិជ្ជកម្មថ្នាក់ជាតិនៃទីក្រុងគុនមីញបានទទួលចំណូលចិត្តពីប្រទេសឡាវ ភូមា និងកម្ពុជាជាដើម ។

ការកសាងនៃ "ក្រវាត់មួយនិងផ្លូវមួយ"នឹងនាំឱ្យទីក្រុងគុនមីញឈានទៅសម័យបើកចំហថ្មីមួយដែលកាន់តែទូលំទូលាយ និងមានកម្រិតកាន់តែខ្ពស់ ។ ឥឡូវនេះ ទីក្រុងគុនមីញកំពុងចូលរួមយ៉ាងសកម្មទៅក្នុងយន្តការសហការនានាដូចជាសហការ"របៀងសេដ្ឋកិច្ចបង់ក្លាដែស-ចិន-ឥណ្ឌា-ភូមា" សហការនៃអនុតំបន់មហាទន្លេមេគង្គ សហការខេត្តយូនណាន-ឥណ្ឌានិងសហការរវាងយូនណាន និងភាគខាងជើងនៃប្រទេសភូមា ឡាវនិងវៀតណាមជាដើម ។ បច្ចុប្បន្ននេះ ទីក្រុងគុនមីញកំពុងខំប្រឹងប្រែងលើកឡើងភាពស្អាតសម្រស់នៃទីក្រុងដោយផ្អែកលើកម្លាំងទូទាំងខេត្តយូនណាន ដើម្បីបម្រុងនឹងការបើកធ្វើនៃពិព័រណ៍ពាណិជ្ជកម្មអាស៊ីខាងត្បូង ។ មជ្ឈមណ្ឌលពិព័រណ៍អន្តរជាតិទានជី កំពុងបម្រុងនឹងទទួលភ្ញៀវពីប្រទេសនានានៅខែមិថុនាខាងមុខនេះតាមស្មានថា ទ្រង់ទ្រាយសម័យនេះនឹងកើនឡើងម្ដងជាងសម័យមុន ៕

ចាំង ហ្វាន

គណៈកម្មាធិការពិព័រណ៍ពាណិជ្ជកម្មអាស៊ីខាងត្បូង នឹងរក្សាទុកកន្លែងតាំងពិព័រណ៍សម្រាប់ប្រទេសនេប៉ាល់

តាមការយកព័ត៌មានពីគណៈកម្មាធិការពិព័រណ៍ពាណិជ្ជកម្មអាស៊ីខាងត្បូង ឱ្យបានដឹងថា ពាណិជ្ជករនៃប្រទេសនេប៉ាល់ ដែលប្រុងនឹងចូលរួមពិព័រណ៍ពាណិជ្ជកម្មអាស៊ីខាងត្បូងទាំងនោះ ប្រហែលនឹងរងការបះពាល់ពីការរញ្ជួយផែនដីខ្លាំងដែលកើតឡើងនៅថ្ងៃ២៥ខែមេសានេះ គណៈកម្មាធិ-ការពិព័រណ៍ពាណិជ្ជកម្មអាស៊ីខាងត្បូងកំពុងស្រាវជ្រាវផែនការជាបន្ទាន់។

ប្រទេសនេប៉ាល់ គឺជាប្រទេសប្រធានបទនៃពិព័រណ៍ពាណិជ្ជកម្មអាស៊ីខាងត្បូង សម័យខាងមុនមានសហគ្រាសជិត ៨០បានមកចូលរួមការតាំងពិព័រណ៍ ។ ផលិតផលសិប្បកម្មនៃប្រទេសនេប៉ាល់ដូចជា កន្សែងរុំក រោមចៀម រូបចម្លាក់ និងគ្រឿងតុបតែងជាដើម បានទទួលចំណូលចិត្តណាស់។ ឆ្នាំនេះ ប្រទេសនេប៉ាល់បានប្រទះរញ្ជួយផែនដីខ្លាំងដ៏មានថ្នាក់ ៨,១ ហើយបានបណ្ដាលឱ្យស្លាប់ និងរងរបួសយ៉ាងធ្ងន់ធ្ងរផង និងការខាតបង់យ៉ាងធ្ងន់ខាងទ្រព្យសម្បត្តិផង។ បច្ចុប្បន្ននេះ នាយកដ្ឋានតាំងពិព័រណ៍នៃខេត្តយូនណាន កំពុងខំប្រឹងទាក់ទងនឹង២ក្រុមហ៊ុនដែលទទួលខុសត្រូវខាងការតាំងពិព័រណ៍នៃប្រទេសនេប៉ាល់ ប៉ុន្តែដោយសារក្នុងប្រទេសនេប៉ាល់មានគ្រោះមហន្តរាយយ៉ាងធ្ងន់នៅមិនទាន់ទទួលការឆ្លើយតបមកវិញទេ។ កាលពីមុននេះ ប្រទេសនេប៉ាល់បានសុំកន្លែងតាំងពិព័រណ៍ចំនួន៩៤ ហើយទទួលខុសត្រូវដោយពីរក្រុមហ៊ុន នៃប្រទេសនេប៉ាល់។ គណៈកម្មាធិការពិព័រណ៍ពាណិជ្ជកម្មអាស៊ីខាងត្បូងនឹងរក្សាទុកកន្លែងតាំងពិព័រណ៍ចំនួនទាំង ៩៤ សម្រាប់ប្រទេសនេប៉ាល់ ហើយសង្ឃឹមថាពាណិជ្ជករនៃប្រទេសនេប៉ាល់នឹងចូលរួមតាមផែនការ។ គណៈកម្មាធិការពិព័រណ៍ពាណិជ្ជកម្មអាស៊ីខាងត្បូងសង្ឃឹមថា តាមពិព័រណ៍ពាណិជ្ជកម្មអាស៊ីខាងត្បូងលើកនេះ នឹងផ្ដល់ឱកាសអភិវឌ្ឍន៍កាន់តែច្រើនសម្រាប់ពាណិជ្ជករចូលរួមការពិព័រណ៍នៃប្រទេសនេប៉ាល់ ឆ្លង នឹងផ្ដល់ការគាំទ្រចំពោះការកសាងឡើងវិញក្រោយគ្រោះមហន្តរាយសម្រាប់ប្រទេសនេប៉ាល់ ៕

យ៉ាង ហុងឈាន់

មកដល់យូនណាន ភ្លក់មើល "ផ្ការីកនៅលើអណ្ដាត"

នៅក្នុងខេត្តយូនណាន ដែលគេដាក់ឈ្មោះជា "នគរវុក្ខជាតិ" មានវុក្ខជាតិសម្រាប់ទស្សនាជាង ២.៥០០ ប្រភេទ អំណោយទាននៃធម្មជាតិនេះបាននាំឱ្យជនជាតិនានានៃខេត្តយូន-ណានបានបង្កើតវប្បធម៌ពិសាផ្កាដោយឡែកៗរបស់ខ្លួន ផ្កាព្រៃដែលធ្លាប់ត្រូវជំនាន់នីមួយៗនៃជនជាតិនានាធ្វើជាម្ហូបនោះមានប្រភេទជាង ១០០ ក្រៅពីផ្កានៃតំបន់កណ្ដាលចិន ប្រជាជនខេត្តយូនណានតែងតែពិសាផ្កាចេក ផ្កាល្ពៅ ផ្កាតែភ្នំ និងផ្កា azaleas ជាដើម ក្នុងចំណោមនេះផ្កា azaleas គឺល្បីល្បាញជាងគេ។ ខេត្តយូនណាន សម្បូរផ្កា azaleas ណាស់ រាល់និទាឃរដូវ នៅលើភ្នំកៅលីកុងសាន និងភ្នំអៃឡាវ-សានជាដើមមានផ្កា azaleas គ្រប់ពណ៌រីកស្គុសស្គាយពាសពេញ ប៉ុន្តែមានតែផ្កាធំពណ៌សអាចសម្រាប់ពិសា ។ តាមនិទានថា នៅក្នុងវត្តហៃយុនជូលើភ្នំស៊ីប៉ាវសាន នៃស្រុកចាន់ឈាន់បានតម្កល់ទុកនូវសៀវភៅរូបមន្តធ្វើម្ហូបពីរជ្ជកាលមីង និងជ្ជកាលឈីង ព្រះសង្ឃទាំងអស់លើភ្នំនេះសុទ្ធតែចេះធ្វើម្ហូបរាប់សិប បែបដោយប្រើផ្កា azaleas ធំពណ៌ស។

ក្នុងគោលបំណងដើម្បីរក្សារសជាតិនៃនិទាឃរដូវនេះ មនុស្សយូនណាន នៅតែប្រើវិធីជ្រក់ដើម្បីផ្ទុកម្ហូបអាហារធ្វើពីផ្កា ។ ស្ករកុលាបមួយបែប ដែលធ្វើតាមវិធីជ្រក់ គឺល្បីឈ្មោះណាស់នៅភាគកណ្ដាលខេត្តយូនណាន : ជាដំបូងត្រូវហាលផ្កាកុលាបឱ្យស្ងួត រួចហាន់ឱ្យតូចល្អិត ហើយកូរជាមួយស្ករក្រហម ដាក់ក្នុងធុងទុកប្រហែល ៥០-៦០ ថ្ងៃ ក៏ពិសាបានហើយ។ នៅរដូវក្ដៅ បើបញ្ចូលស្ករកុលាបទៅក្នុងទឹកល្ហុងផ្អែម ឬគ្រឿងភេសជ្ជៈផ្សេងទៀត ពិតជាឆ្ងាញ់ណាស់។ នំផ្កាស្រស់ដែលជាវត្ថុអនុស្សាវរីយ៍ដ៏ពេញនិយមមួយបែបនៃខេត្តយូនណាន ក៏ធ្វើពីស្ករកុលាបនេះដែរ គឺជានំមួយបែបឆ្ងាញ់ និងស្រួយណាស់ ហើយចោលក្លិនក្រអូបនៃផ្កាកុលាប ៕

យ៉ាង យ៉ាន់

ព្រលានយន្តហោះបឹងលូគូហ៊ូ នៃស្រុកនីងឡាំង នឹងចាប់ប្រើការនៅក្នុងឆ្នាំនេះ

បច្ចុប្បន្ននេះ នាយកដ្ឋានអាកាសចរណ៍ស៊ីវិលចិនបានអនុម័ត និងយល់ព្រមថា ព្រលានយន្តហោះថ្មីនៃស្រុកនីងឡាំង ត្រូវដាក់ឈ្មោះជាព្រលានយន្តហោះបឹងលូគូហ៊ូនៃស្រុកនីងឡាំង ដែលឈ្មោះភាសាអង់គ្លេស គឺ NINGLANG LUGUHU AIRPORT។

ព្រលានយន្តហោះបឹងលូគូហ៊ូ គឺព្រលានយន្តហោះក្នុងតំបន់នៃប្រទេសចិន ចាប់ផ្ដើមសាងសង់ថ្ងៃ២៤ខែមេសាឆ្នាំ២០១៣ តាមគម្រោងការនឹងអាចដឹកជញ្ជូនអ្នកភ្ញៀវ៤៥០.០០០នាក់ និងទំនិញ ៩០០ តោនដល់ឆ្នាំ២០២០។ ឥឡូវនេះ ការសាងសង់នៃព្រលានយន្តហោះបឹងលូគូហ៊ូកំពុងត្រូវបានជំរុញ ដោយខំប្រឹងពេញទំហឹង ដើម្បីចាប់ប្រើការនៅពេលថ្ងៃបុណ្យជាតិឆ្នាំនេះ។

បឹងលូគូហ៊ូ គឺជាបឹងខ្ពង់រាបមួយនៃបឹងខ្ពង់រាបធំជាងគេទាំងប្រាំបួននៃប្រទេសចិន វាស្ថិតនៅតំបន់ភ្ជាប់ដែននៃខេត្តយូនណាន និងខេត្តស៊ីឈាន់ បានថែរក្សាគុណភាពទឹកថ្នាក់ទី១ ជានិច្ច ល្បីឈ្មោះដោយសារមានទេសភាពស្រស់ស្អាត និងវប្បធម៌ជនជាតិភាគតិចពិសេស។ ជន "ម៉ូសួ" ដែលរស់នៅជុំវិញបឹងលូគូហ៊ូ នៅបានរក្សាទំនៀមទម្លាប់នៃសង្គម Matriarchal ហេតុនេះត្រូវគេស្គាល់ជា "នគរស្រីនៅទិសខាងកើត"៕

សាវ ជា